KHMER

AEC
Australian Electoral Commission

# ឈប់ ហើយពិចារណា

## ចូរពិនិត្យមើលប្រភពនៃការបោះឆ្នោតសហព័ន្ធនេះ

ក្នុងអំឡុងពេលបោះឆ្នោតសហព័ន្ធ មានចំនួនព័ត៌មានជាច្រើនដែលកំពុងត្រូវបានចែកចាយ ហើយកំពុងព្យាយាមដើម្បីដាក់ឥទ្ធិពលលើការបោះឆ្នោតរបស់លោកអ្នក។ វាសំខាន់ដែលលោកអ្នកពិចារណាពីអ្វីដែលលោកអ្នកមើលឃើញ ស្តាប់ឮ ឬអាន។ ប្រសិនបើលោកអ្នកមានការសង្ស័យអំពីព័ត៌មាននោះ មានសំណួរដែលលោកអ្នកអាចសួរនាំ ដើម្បីជួយលោកអ្នកបង្កើតគំនិតផ្ទាល់ខ្លួនរបស់លោកអ្នក ហើយធ្វើការសម្រេចចិត្ត។

## តួនាទីរបស់លោកអ្នកជាអ្នកបោះឆ្នោត

ចូរចំណាយពេលដើម្បីពិចារណា ប្រសិនបើព័ត៌មាននោះ៖

### អាចទុកចិត្តបាន

**តើវាមកពីប្រភពដែលអាចទុកចិត្ត ឬស្គាល់បានឬ?**

តើលោកអ្នកដឹងពីប្រភពនៃព័ត៌មាននោះឬទេ? តើវាមកពីប្រព័ន្ធផ្សព្វផ្សាយដែលរដ្ឋទទួលស្គាល់ជាផ្លូវការ ឬគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមដែលបានបញ្ជាក់ផ្ទៀងផ្ទាត់ឬ?

ច្បាប់គ្រប់គ្រងការបោះឆ្នោត មិនត្រួតពិនិត្យលើភាពត្រឹមត្រូវនៃការទាក់ទងឡើយ។

### បច្ចុប្បន្នភាព

**តើវាត្រូវបានបោះពុម្ពផ្សាយនៅពេលណា?**

គ្រាន់តែមានសេចក្តីប្រកាស / អត្ថបទ ត្រូវបានចែករំលែកនៅថ្ងៃនេះ មិនមែនមានន័យថាវាបច្ចុប្បន្នទេ។ ជានិច្ចកាល ចូរពិនិត្យមើលប្រភពដើម និងកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ។

### សុវត្ថិភាព

**តើវាអាចជាករណីឆបោកឬ?**

ប្រសិនបើលោកអ្នកមានការសង្ស័យអំពីប្រភព ឬមាតិកានៃព័ត៌មានដែលត្រូវបានទាក់ទងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ឬប្រព័ន្ធឌីជីថលផ្សេងទៀត វាជាការសំខាន់ដែលត្រូវគិតដោយប្រុងប្រយ័ត្ន មុនពេលទាក់ទិន។

ពេលណាអាចធ្វើទៅបាន លោកអ្នកគួរពិនិត្យមើលព័ត៌មានទំនាក់ទំនងលម្អិតនៃប្រភពព័ត៌មាននោះ។

## តួនាទីរបស់ AEC

គណៈកម្មការរៀបចំការបោះឆ្នោតអូស្ត្រាលី (AEC) គឺជាភ្នាក់ងារឯករាជ្យដែលមានតួនាទីគ្រប់គ្រងការបោះឆ្នោតសហព័ន្ធ។ តួនាទីរបស់ AEC គឺដើម្បី៖

**ផ្តល់ព័ត៌មានដែលអាចទុកចិត្តបាន អំពីដំណើរការបោះឆ្នោត**

AEC នឹងផ្តល់នូវភាពងាយស្រួលក្នុងការទទួលបានព័ត៌មានទាក់ទង នឹងរបៀបចុះឈ្មោះបោះឆ្នោត ឬតែងតាំងជាបេក្ខជនសម្រាប់ការបោះឆ្នោត តាមរយៈយុទ្ធនាការផ្សព្វផ្សាយពាណិជ្ជកម្ម វិបសៃថ៍ មជ្ឈមណ្ឌលទំនាក់ទំនង និងគណនីប្រព័ន្ធផ្សព្វផ្សាយសង្គម។

ប្រសិនបើមានព័ត៌មានមិនត្រឹមត្រូវណាមួយ អំពីដំណើរការបោះឆ្នោត ទាំងនេះ AEC នឹងចាត់វិធានការដើម្បីកែតម្រូវកំណត់ត្រា។ នៅខាងក្រៅដំណើរការបោះឆ្នោតទាំងនេះ – AEC មិនមានតួនាទីណាមួយ ក្នុងត្រួតពិនិត្យលើភាពត្រឹមត្រូវនៃការបោះឆ្នោតឡើយ។

**ស៊ើបអង្កេតការអនុញ្ញាតនៃទំនាក់ទំនងការបោះឆ្នោត**

ទំនាក់ទំនងការបោះឆ្នោតជាក់លាក់ចំនួន ត្រូវបានតម្រូវឱ្យមានការអនុញ្ញាត ដើម្បីជួយលោកអ្នកឱ្យបានដឹងពីប្រភពនៃព័ត៌មាននោះ។ នៅពេលទទួលបានពាក្យបណ្តឹងតវ៉ា AEC នឹងធ្វើការស៊ើបអង្កេតទំនាក់ទំនងការបោះឆ្នោតដែលមិនបានអនុញ្ញាតដោយត្រឹមត្រូវ។




aec.gov.au 13 23 26

អនុញ្ញាតដោយស្នងការរៀបចំការបោះឆ្នោត ទីក្រុង Canberra
Authorised by the Electoral Commissioner, Canberra